# ការសំភាសន៍របស់ ម៉ាក់យាយ អ៊ុំ ម៉ុន

កៈ អ្នកដែរសំភាសន៍គេមានជាង ស៊ីអ៊ាវ ខៈ អ្នកដែរអោយគេសំភាសន៍មាន អ៊ុំ ម៉ុន

## <u>ការសង្ខេបប្រវត្តិរបស់ ម៉ាក់យាយ អ៊ុំ ម៉ុន</u>

ម៉ាក់យាយ អ៊ុំ ម៉ុន អាយុ 67នៅឆ្នាំ 2018 ម៉ាក់យាយ អ៊ុំ ម៉ុន មានភេទស្រី ម៉ាក់យាយ អ៊ុំ ម៉ុន មានទីលំនៅបច្ចុប្បន្ន នៅភូមិ5 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញ។

កៈ ចឹងជាដំបូងខ្ញុំអរគុណម៉ាក់យាយដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់ម៉ាក់យាយ ហើយការសំភាសន៍មួយនឹងត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថា BYUហាសម៉ាក់ ហើយសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរហាស ដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗដើម្បីអោយពួកគាត់បានស្គាល់នឹងបានដឹងពីប្រវត្តិឪពុកម្ដាយ នឹងដូនតាចឹងហាសម៉ាក់យាយ បាទចឹងនៅពេលដែរខ្ញុំបានសំភាសន៍ម៉ាក់យាយហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសម៉ាក់យាយ ចឹងសំរាប់ម៉ាក់យាយយល់ព្រម ដើម្បីអោយខ្ញុំដាក់ការសំភាសន៍មួយនឹងទៅក្នុងវេបសាយរបស់សាលាដែរទេម៉ាក់យាយ?

ខៈ ខ្ញុំវាអត់ដែលហាសកូន

កៈ ប៉ុន្តែម៉ាក់យាយយល់ព្រមដើម្បីអោយខ្ញុំសំភាសន៍ម៉ាក់យាយហើយ ហើយដាក់ការសំភាសន៍មួយនឹងទៅក្នុងវេបសាយបស់សាលាដើម្បីតំកល់ទុកអោយម៉ាក់យាយដែរទេ?

ខៈ ចា៎!មិនអីទេ

កៈ បាទចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍ម៉ាក់យាយខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ាវ ហើយថ្ងៃខែដែរខ្ញុំសំភាសន៍ម៉ាក់យាយគឺនៅថ្ងៃទី7 ខែ2 ឆ្នាំ2018 ហើយការសំភាសន៍នេះធ្វើឡើងនៅភូមិ5 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញ ចឹងសំរាប់ម៉ាក់យាយមានឈ្មោះពេញរបស់ម៉ាក់យាយមានឈ្មោះអីគេដែរម៉ាក់យាយ?

ខៈ ខ្ញុំឈ្មោះអ៊ុំ ម៉ុន

ក៖ ឈ្មោះ មានឈ្មោះហៅក្រៅទេ ម៉ាក់យាយ?

ខ៖ អត់មានទេ មានឈ្មោះតែមួយនឹង

ក៖ ចុះកាលពីក្មេងធ្លាប់មាននរណាហៅឈ្មោះម៉ាក់យាយអីផ្សេងទេ?

ខ៖ អត់មានទេ

ក៖ អត់មានទេណាម៉ាក់យាយ?

ខ៖ ចាំ!អត់មាន

ក៖ ចុះម៉ាក់យាយសព្វថ្ងៃនឹងម៉ាក់យាយអាយុប៉ុន្មានដែរម៉ាក់យាយ ?
ខ៖ ខ្ញុំអាយុ67ឆ្នាំ

ក៖ ចុះម៉ាក់យាយកើតនៅថ្ងៃខែឆ្នាំណាដែរម៉ាក់យាយចាំទេ?

ខ៖ ខ្ញុំអត់បានចាំដែរនឹងហាស

ក៖ ចឹងម៉ាក់យាយកើតនៅឆ្នាំ1951ចឹងហាសម៉ាក់យាយ?

ខ៖ ចាំ!នឹងហើយ

ក៖ ចុះម៉ាក់យាយបើនិយាយពីឆ្នាំច័ន្ទគតិវិញ នៅឆ្នាំជូត ឆ្លូវ ខាល ថោះម៉ាក់យាយកើតនៅឆ្នាំអីគេដែរម៉ាក់យាយ?

ខ៖ ខ្ញុំកើតនៅឆ្នាំថោះ

ក៖ នៅឆ្នាំថោះណាម៉ាក់ ចុះម៉ាក់យាយកើតនៅភូមិអី ឃុំអី ស្រុក ខេត្តអីម៉ាក់យាយ?

ខ៖ ខ្ញុំកើតនៅខេត្តស្វាយរៀង

ក៖ ប៉ុន្តែភូមិអី ឃុំអីគេដែរម៉ាក់យាយ?

ខ៖ នៅស្រុកកំពង់រ៉ូល នៅបន្ទាយក្រាំង

ក៖ បន្ទាយក្រាំងនឹងភូមិ រឺមួយក៏ឃុំដែរម៉ាក់យាយ?

ខ៖ ឃុំបន្ទាយក្រាំង

ក៖ ចុះភូមិអីគេដែរម៉ាក់យាយ?

ខ៖ នៅស្រុកចន្ទ្រា

ក៖ នៅស្រុកចន្ទ្រា នៅកំពង់រ៉ូល រឺមួយក៏នៅស្រុកចន្ទ្រាដែរម៉ាក់យាយ?

ខ៖  នៅចន្ទ្រា

ក៖  នៅស្រុកចន្ទ្រា នៅខេត្តស្វាយរៀង?

ខ៖  នឹងហើយនៅខេត្តស្វាយរៀង

ក៖  ចុះម៉ាក់យាយមានបងប្អូនចំនួនប៉ុន្មាននាក់ដែរម៉ាក់យាយ?

ខ៖  បងប្អូននៅសល់5នាក់ នឹងម្ដាយចាស់មួយ

ក៖  អូ ចុះពីមុននឹងទាំងអស់តែម្ដងនឹងបងប្អូនម៉ាក់យាយនឹងប៉ុន្មាននាក់ដែរ?

ខ៖  បើនិយាយទាំងអស់នឹងមានបងប្អូនចំនួន12នាក់

ក៖  អូ៎!មានបងប្អូន12នាក់ច្រើនហាសណាស់ម៉ាក់យាយ?

ខ៖  ចា៎!ច្រើនតា

ក៖  តែឥឡូវនឹងនៅសល់តែ5នាក់ទេ?

ខ៖  នៅសល់តែ5នាក់នឹងហាស

ក៖  ប៉ុន្តែម៉ាក់យាយជាកូនទីប៉ុន្មានដែរម៉ាក់យាយ?

ខ៖  ខ្ញុំជាកូនបងគេ

ក៖  ម៉ាក់យាយបងគេ ចុះបងប្អូនរបស់ម៉ាក់យាយនឹងមានស្រីប៉ុន្មាន ហើយនឹងប្រុសប៉ុន្មាននាក់ដែរម៉ាក់យាយមានចងចាំទេ?

ខ៖  មានប្រុស2នាក់

ក៖  មានប្រុស2នាក់ នឹងស្រីប៉ុន្មាននាក់ដែរម៉ាក់យាយ?

ខ៖  ប៉ុន្តែអាស្លាប់ៗនឹងវាអស់ហើយនៅសល់តែស្រី មានប្អូនស្រីមួយទើបតែស្លាប់ ចឹងមាននៅសល់បងប្អូនសស្រី4នាក់ នឹងប្រុស1នាក់

ក៖  ប្រុសនៅសល់តែមួយទេ ចុះអ្នកដែរស្លាប់នឹងម៉ាក់យាយនៅចងចាំឈ្មោះពួកគាត់ដែរទេម៉ាក់យាយ?

ខ៖  ឈ្មោះចាំតា

ក៖  ចឹងម៉ាក់យាយនៅចងចាំឈ្មោះបងប្អូនរបស់ម៉ាក់យាយទាំងអស់ហោសម៉ាក់យាយ?

ខ៖  ចា៎!ចាំតេ

កៈ ចុះម៉ាក់យាយអាចរៀបរាប់ទាំងអស់បានទេ?

ខៈ បានដែរតើ

កៈ ចុះពួកគាត់មានឈ្មោះអីគេខ្លះដែរម៉ាក់យាយ?

ខៈ មានប្អូនមួយឈ្មោះ អាសុខ បងពីខ្ញុំនឹងឈ្មោះគង់ បន្ទាប់មកមានប្អូនប្រុសមួយឈ្មោះអាសុខ

កៈ ចុះបន្ទាប់មកទៀតម៉ាក់យាយ?

ខៈ បន្ទាប់មកទៀតឈ្មោះយាយ វ៉ាយ បន្ទាប់ពីខ្ញុំមកវិញហាស

កៈ បាទម៉ាក់យាយ?

ខៈ ហើយបានប្អូនរបស់ខ្ញុំឈ្មោះយាយ មឿន បន្ទាប់មកប្អូនរបស់ខ្ញុំទៀតឈ្មោះអាយូង ហើយមួយទៀតឈ្មោះហុច

កៈ ឈ្មោះយាយ ហុច?

ខៈ តែប្អូនពៅរបស់ខ្ញុំអាណាស្លាប់នឹងខ្ញុំអត់គិតទេណាស់

កៈ អូ៎!បាទប៉ុន្តែម៉ាក់យាយមានចងចាំឈ្មោះពួកគាត់ដែរស្លាប់ទេ?

ខៈ ខ្ញុំចាំដែរតា

កៈ ពួកគាត់មានឈ្មោះអីគេខ្លះដែរទៅម៉ាក់យាយ?

ខៈ ឈ្មោះអ៊ុំ អែម

កៈ អ៊ុំ អែម ចុះផ្សេងទៀតដែរម៉ាក់យាយ?

ខៈ អត់មានទេ

កៈ អូ៎!អត់មានទេ ចុះម៉ាក់យាយមានចងចាំអនុស្សាវរីយ៍អីកាលពីម៉ាក់យាយនៅក្មេងអាយុ4-10ឆ្នាំអីម៉ាក់យាយធ្លាប់ធ្វើអីជាមួយពួកគាត់ដែរចឹងហាស?

ខៈ ខ្ញុំគ្មានធ្លាប់ធ្វើអីចំពោះឪពុករបស់ខ្ញុំទេ

កៈ អត់ទេម៉ាក់យាយ ដូចជាម៉ាក់យាយធ្លាប់លេងឡឹកបាយឡ រឺមួយលេងថុយអីជាមួយបងប្អូនរបស់ម៉ក់យាយទេ?

ខ៖ លេងតា

ក៖ ចុះលេងអីគេខ្លះដែរម៉ាក់យាយ?

ខ៖ លេងឡឹកបាយឡអីចឹងទៅណាស់ នាំបងប្អូនដាំស្លដាមួយចានឆ្នាំ លេងជាមួយកូនចានអីចឹងហាសណាស់

ក៖ ចុះម៉ាក់យាយមានធ្លាប់ធ្វើអីជាមួយពួកគាត់ទៀតទេ ដូចជាលេងលោតអន្ទាក់ លេងលោតកៅស៊ូអីចឹងហាស?

ខ៖ អត់អត់ចេះទេ

ក៖ ចុះធ្លាប់មានលេងបិទពួន លេងសាញ៉េ?

ខ៖ បើលេងសាញ៉េ លេងដណ្ដើមស្លឹកឈើមានតា បើថាលេងលោតអន្ទាក់លោតអីនឹងអត់ដែរទេនឹងហាស

ក៖ អត់ដែរទេហោសម៉ាក់យាយ?

ខ៖ អត់ដែរទេ

ក៖ ចុះម៉ាក់យាយធ្លាប់ដើរលេងទៅស្រែអីជាមួយបងប្អូនរបស់ម៉ាក់យាយទេ?

ខ៖ អត់ដែរសោះ

ក៖ ចុះម៉ាក់យាយគិតថា ម៉ាក់យាយចូលចិត្តលេងអីជាមួយបងប្អូនរបស់ម៉ាក់យាយជាងគេដែរម៉ាក់យាយ?

ខ៖ អត់លេងទេ លេងតែឡឹកបាយឡនឹងហាស

ក៖ ចឹងម៉ាក់យាយលេងតែឡឹកបាយឡនឹងសប្បាយណាម៉ាក់យាយ?

ខ៖ ចាំ!សប្បាយដែរ

ក៖ ចុះបងប្អូនរបស់ម៉ាក់យាយដែរនៅរស់នឹងពួកគាត់នៅណាដែរម៉ាក់យាយ?

ខ៖ គេនៅស្ទឹងមានជ័យហោស

ក៖ នៅស្ទឹងមានជ័យហោសម៉ាក់យាយ ទាំងអស់គ្នាតែម្ដងនឹងហោស?

ខ៖ ទាំងអស់គ្នានឹងម្ដាយរបស់ខ្ញុំគាត់នៅជុំគ្នាទាំងអស់គ្នានឹងហាស

ក៖ អត់មាននរណាគេនៅស្រុកទេហោសម៉ាក់យាយ?

ខ៖ អត់មានទេ

ក៖ ពួកគាត់ធ្វើអីគេនៅស្ទឹងមានជ័យនឹងហោស?

ខ៖ គាត់នៅរកស៊ីយើងធម្មតានៅលក់នុំបញ្ចុះអីនឹងហាស មានកំប៉េកកំប៉ុកអីទៅណាស់

ក៖ ទាំងអស់គ្នាតែម្តងនឹងហោសម៉ាក់?

ខ៖ ទាំងអស់គ្នានឹង ហើយនឹងទៅរកអេតចាយអីចឹងទៅណាស់

ក៖ ចុះឪពុករបស់ម៉ាក់យាយមានឈ្មោះអីគេដែរម៉ាក់យាយ?

ខ៖ ឪពុករបស់ខ្ញុំឈ្មោះអ៊ុំ អែមនឹងហាស

ក៖ គាត់ឈ្មោះអ៊ុំអែមណាម៉ាក់យាយ ចុះគាត់អាយុប៉ុន្មានដែរម៉ាក់យាយចងចាំទេ?

ខ៖ គាត់អាយុ73ឆ្នាំ

ក៖ គាត់អាយុ73ឆ្នាំហោសម៉ាក់យាយ?

ខ៖ ចា៎!គាត់អាយុ73ឆ្នាំគាត់បានស្លាប់បាត់ទៅ គាត់ស្លាប់នៅជំនាន់អាពតនឹងហាស

ក៖ ចុះម្តាយរបស់ម៉ាក់យាយដែរ?

ខ៖ ម្តាយរបស់ខ្ញុំនឹងគាត់នៅរស់សព្វថ្ងៃនឹងហាស គាត់អាយុ93ឆ្នាំ

ក៖ ចុះគាត់កើតនៅថ្ងៃខែឆ្នាំណាម៉ាក់យាយ មានចងចាំទេ?

ខ៖ ខ្ញុំអត់បានចាំទេ ខ្ញុំអត់បានសួរគាត់ផងនឹង

ក៖ ចឹងចុះឪពុករបស់ម៉ាក់យាយ គាត់កើតនៅណាដែរម៉ាក់យាយ?

ខ៖ គាត់កើតនៅស្វាយរៀង

ក៖ គាត់កើតនៅស្វាយរៀងតែម្តងនឹងហោសម៉ាក់យាយ?

ខ៖ នឹងហើយនៅណុង

ក៖ ចុះម្តាយរបស់ម៉ាក់យាយវិញ?

ខ៖ ម្តាយរបស់ខ្ញុំក៏នៅស្វាយរៀងដែរនឹងហាស

ក៖ ចឹងសំរាប់ម្តាយរបស់ម៉ាក់យាយកើតៅឆ្នាំ1925

ខ៖ ចា៎!នឹងហើយ

កៈ ចុះឪពុករបស់ម៉ាក់យាយគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរម៉ាក់យាយពេលដែរគាត់នៅរស់ហាស?

ខៈ គាត់ជាងកាត់សក់

កៈ អូ៎!គាត់ជាងកាត់សក់ហោស?

ខៈ គាត់ជាងធ្វើផ្ទះ នឹងជាងកាត់សក់

កៈ ចឹងមានន័យថាគាត់ចេះធ្វើផ្ទះហើយគាត់កាត់សក់ទៀត?

ខៈ មានគេមកកាត់សក់ទៅគាត់កាត់សក់ទៅ ពេលដែរគ្មានគេកាត់សក់ចឹងគេហៅអោយទៅធ្វើផ្ទះចឹងគាត់ទៅធ្វើផ្ទះចឹងទៅណាស់

កៈ ចុះឪពុករបស់ម៉ាក់យាយគាត់ស្លូត រឺមួយក៏កាចដែរម៉ាក់យាយ?

ខៈ អត់អីទេ ឪពុករបស់ខ្ញុំគាត់ស្លូតណាស់

កៈ អូ៎!ចឹងម្តាយក៏ស្លូតដែរ?

ខៈ ចា៎!ស្លូតទេ

កៈ ចុះម្តាយម៉ាក់យាយគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរម៉ាក់យាយ?

ខៈ នៅពេលដែរគាត់មិនទាន់បាក់ភ្លៅអីចឹងទៅ គាត់បានរែកនុំបញ្ចុះលក់ទៅ

កៈ ចឹងមានន័យថាម្តាយម៉ាក់យាយនឹង បាទម៉ាក់យាយ?

ខៈ នៅស្រុកស្រែនឹង គាត់ធ្វើតែស្រែទេ

កៈ អូ៎!គាត់ធ្វើតែស្រែទេ ចុះម្តាយរបស់ម៉ាក់យាយឥឡូវនឹងគាត់ឈឺភ្លៅមែនម៉ាក់យាយ?

ខៈ គាត់បានធ្លាក់ពីលើគ្រែចឹងគាត់បានបាក់ត្រគាកហាស សព្វថ្ងៃនឹងគាត់ងងឹតភ្នែកគាត់មើលអីមិនឃើញទេនឹងហាស

កៈ គាត់អាយុកៅជាងហើយណាម៉ាក់យាយ?

ខៈ ចា៎!ហើយគាត់វង្វេងហើយសឹងតែមួយយប់ទល់ៗភ្លឺនឹងហាស

កៈ អូ៎!គាត់វង្វេងដែរហោសម៉ាក់យាយ?

ខៈ ចា៎!នឹងហើយ

កៈ ចុះម៉ាក់យាយមានចងចាំ
សាច់រឿងអីកាលពីម៉ាក់យាយនៅជាមួយឪពុកម្ដាយរបស់ម៉ាក់យាយដែរទេ
ធ្លាប់ធ្វើអីគេខ្លះនឹងធ្លាប់រកស៊ីអីជាមួយគេខ្លះចឹងហាស?

ខៈ ខ្ញុំមិនដែរមានចងចាំអីជាមួយឪពុកម្ដាយរបស់ខ្ញុំទេ
ខ្ញុំស្រលាញ់ឪពុកម្ដាយរបស់ខ្ញុំណាស់ ខ្ញុំមិនដែរអោយខុសឆ្គងពីឪពុកម្ដាយរបស់ខ្ញុំទេ

កៈ ប៉ុន្តែម៉ាក់យាយមានធ្លាប់ចងចាំថាទៅធ្វើការ រឺមួយទៅស្រែ
ដែរជាអនុស្សាវរីយ៍អីជាមួយឪពុកម្ដាយដែរចាំអត់ភ្លេចហាសម៉ាក់យាយ?

ខៈ ខ្ញុំចាំរឿងធ្វើស្រែនឹងស្ទូងដកអីចឹងហាស ដល់ពេលដែរយើងធ្វើស្រែ ក៏ធ្វើស្រែទៅ
ដល់រដូវយើងច្រូតក៏ច្រូតទៅចឹងហាសណាស់ ខ្ញុំមានចងចាំតែប៉ុណ្ណឹងទេកូន

កៈ មានរឿងអីផ្សេងទៀតទេ ដែរម៉ាក់យាយគិតថាម៉ាក់យាយទៅវត្តអីចឹងហាស
ដែរម៉ាក់យាយចងចាំអត់ភ្លេចចឹងហាស?

ខៈ ទៅម៉ែហៅទៅចឹងក៏ទៅតាមម្ដាយចឹងទៅណាស់

កៈ ចុះម៉ាក់យាយគិតថាមានចងចាំអីពីនឹងផ្សេងទៀតទេ?

ខៈ គ្មានទេ

កៈ ចុះសំរាប់ម្ដាយឪពុករបស់ម៉ាក់យាយ
គាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅម៉ាក់យាយទេ?

ខៈ គាត់ប្រាប់ដែរនឹង

កៈ គាត់ប្រាប់ថាម៉េចខ្លះទៅម៉ាក់យាយ?

ខៈ គាត់ប្រាប់ថាកាលពីគាត់ការជាមួយឪពុករបស់ខ្ញុំនឹង
គាត់ថាកូនអើយម៉ែពីមុនមិនសប្បាយដូចកូនរាល់ថ្ងៃចឹងទេណាស់កូន

កៈ ម៉េចចឹងម៉ាក់យាយ?

ខៈ គាត់ថាពីមុនគេបាននឹងគេត្បាញ ភួយ ត្បាញមុងយកមកស្លៀក
គេយកមកធ្វើជាសំពត់អីចឹងហាសដើម្បីយកធ្វើជាបញ្ច័យហាស គាត់ប្រាប់ចឹងមែន

កៈ បាទចឹងហោសម៉ាក់យាយ?

ខ៖ នឹងប្រវត្តិរបស់គាត់ គាត់ថាប្រវត្តិគាត់ពីមុនក្រណាស់ គាត់ថាគាត់ដាំបាយឆ្នាំដីហាស ប្រវត្តិគាត់ពីមុនហាសកូន គាត់ថាសម័យគាត់ដាំបាយឆ្នាំដី តែដល់ពេលសម័យឥឡូវនឹង គេដាំបាយឆ្នាំភ្លើង នឹងចង្ក្រានហ្គេសអីចឹងទៅណាស់

ក៖ បាទត្រូវម៉ាក់យាយ

ខ៖ ជំនាន់ណុងកាលពីគាត់ការជាមួយឪពុករបស់ខ្ញុំនឹង គាត់ថាគាត់ស្លៀកភួយ នឹងស្លៀកប៉ាវវាចឹងហាស

ក៖ ចុះយាយតាខាងម្តាយម៉ាក់យាយមានចងចាំឈ្មោះពួកគាត់ដែរទេ?

ខ៖ តាខាងម្តាយឈ្មោះតាស៊ីវ

ក៖ ចុះយាយវិញម៉ាក់យាយ?

ខ៖ ឈ្មោះ យាយអ៊ុច

ក៖ ចុះយាយតាខាងឪពុកវិញម៉ាក់យាយ?

ខ៖ តាខាងឪពុកនឹងឈ្មោះតាអ៊ុំ

ក៖ ចុះយាយវិញឈ្មោះយាយអីគេដែរម៉ាក់យាយ?

ខ៖ ខ្ញុំបានភ្លេចឈ្មោះគាត់ហើយនឹងហាស គាត់យូរពេក

ក៖ ចុះគាត់អាយុប៉ុន្មានៗម៉ាក់យាយអត់មានចងចាំទេ?

ខ៖ អត់មានចងចាំទេ ពីព្រោះគាត់យាយរបស់ខ្ញុំវៀតណាមយួនទេណាស់ គាត់នៅព្រេងអង្គរ ដល់ពេលគាត់ស្លាប់នឹងក៏គាត់ទៅស្លាប់នៅព្រេងអង្គរនឹងដែរ សូម្បីតែសំលេងក៏ខ្ញុំមិនទាន់ដែរនឹងហាស

ក៖ អ៊ូ!ចឹងហោសម៉ាក់យាយ?

ខ៖ គាត់ទៅស្លាប់ជាមួយបងប្អូនរបស់គាត់នៅព្រេងអង្គរនឹងទេណាស់

ក៖ បាទម៉ាក់យាយចុះសំរាប់យាយតារបស់ម៉ាក់យាយគាត់កើតនៅណាម៉ាក់យាយមានដឹងទេ?

ខ៖ យាយកើតនៅព្រេងអង្គរ

ក៖ ចុះតាវិញ?

ខ៖  គាកើតនៅស្វាយរៀង

ក៖  ចុះនឹងខាងឪពុករឺមួយខាងម្ដាយដែរម៉ាក់យាយ?

ខ៖  នឹងខាងឪពុក

ក៖  ចុះខាងម្ដាយវិញ?

ខ៖  ខាងម្ដាយគាត់កើតនៅស្វាយរៀងទាំងអស់នឹងហាស នៅភូមិខ្ញុំថាមិញនឹងនៅស្រុកណុង

ក៖  ចុះម៉ាក់យាយមកនៅទីក្រុងភ្នំពេញនឹងយូរនៅម៉ាក់យាយ?

ខ៖  ខ្ញុំមកនៅតាំពីឆ្នាំ1979 តាំងពីបែកអាពតនឹងមក

ក៖  ចឹងមានន័យថាប្រហែលជាជាងសាមសិប ទៅសែសិបហើយមើលទៅ?

ខ៖  បើសរុបទៅវាសែសិបឆ្នាំជាងហើយនឹងហាស តាំងពីយើងបែកឆ្នាំ1979ហ៊ី

ក៖  នៅឆ្នាំ1979មក?

ខ៖  នឹងហើយតាំងពីវៀតណាមចូលមកនឹងវាឆ្នាំ1979 ដល់ឆ្នាំ2017នឹងហាស

ក៖  ឆ្នាំ2018នឹង?

ខ៖  ឆ្នាំ2018

ក៖  ចុះម៉ាក់យាយមានបងប្អូនរឺមួយក៏កូនចៅណាដែរទៀរស់នៅក្រៅប្រទេសទេ?

ខ៖  អត់មានទេ

ក៖  នៅវៀតណាម ថៃអីក៏អត់មានដែរ?

ខ៖  អត់មានទេ

ក៖  អូ៎!បាទម៉ាក់យាយ ចុះស្វាមីរបស់ម៉ាក់យាយមានឈ្មោះអីគេដែរម៉ាក់យាយ?

ខ៖  គាត់ឈ្មោះសុខ សុភ័ណ ប៉ុន្តែគាត់ស្លាប់បាត់ហើយ

ក៖  ចុះម៉ាក់យាយមានចងចាំថ្ងៃខែឆ្នាំ ដែរម៉ាក់យាយរៀបអាពាហ៍ពិពាហ៍ដែរទេ?

ខ៖  ខ្ញុំអតមានចាំទេ ខ្ញុំភ្លេចអស់ហើយនឹងហាស

ក៖  ចុះម៉ាក់យាយមានដឹងថាកូនបងរបស់ម៉ាក់យាយមានអាយុប៉ុន្មានដែរម៉ាក់យាយ?

ខ៖ កូនរបស់ខ្ញុំកូនបងឆ្នាំខាល

ក៖ ប៉ុន្តែអាយុប៉ុន្មានដែរម៉ាក់យាយ?

ខ៖ ជាងអាយុសែហើយនឹងហាស

ក៖ ចឹងវាជិតសែសិប
ចឹងមានន័យថាម៉ាក់យាយការអស់ជិតសែសិបឆ្នាំហើយណាម៉ាក់យាយ?

ខ៖ ចាំ!នឹងហើយ

ក៖ បាទម៉ាក់យាយ
ចុះនៅពេលដែរម៉ាក់យាយរៀបអាពាហ៍ពិពាហ៍នឹងគិតថាឪពុកម្តាយរបស់ម៉ាក់យាយជាអ្នករៀបអោយ រឺមួយក៏ម៉ាក់យាយជាអ្នករៀបចំដោយខ្លួនឯងដែរ?

ខ៖ ឪពុកម្តាយជាអ្នករៀបចំហាស

ក៖ ចុះពេលណុងមានជាថ្លៃទឹកដោះទេម៉ាក់យាយ?

ខ៖ មានតា ប៉ុន្តែវាបានតិចនឹងហាស

ក៖ បានប្រហែលជាប៉ុន្មានដែរម៉ាក់យាយ?

ខ៖ កាលពីជំនាន់ណុងបានតែ30ម៉ឺននឹង

ក៖ បាន30ម៉ឺនច្រើនហាសណាស់ម៉ាក់យាយ?

ខ៖ មិនជាច្រើនទេ

ក៖ ចុះម៉ាក់យាយអាចប្រាប់ប្រវត្តិថាម៉ាក់យាយស្រលាញ់គ្នានៅពេលណា ហេតុអីបានជាតាចូលស្តីម៉ាក់យាយ ហើយស្គាល់អស់រយះពេលប៉ុន្មានឆ្នាំដែរ?

ខ៖ ប្រវត្តិតាហើយនឹងខ្ញុំនឹងគាត់ស្រលាញ់ខ្ញុំជិត2ឆ្នាំ

ក៖ អូ៎!តាចូលស្តីហោស?

ខ៖ នឹងហើយ

ក៖ ចុះហេតុអីបានតាចូលស្តីម៉ាក់យាយដែរចឹងហាស?

ខ៖ ចុះនរណាដឹងរឿងគាត់ដែរ

ក៖ ពេលខ្លះគឺឡូយាយស្អាតជាងគេក្នុងភូមិអីចឹងហាស?

ខ៖ ស្អាតអីខ្ញុំអាក្រក់ចង់ស្លាប់ហើយនឹង

ក៖ ចុះម៉ាក់យាយធ្លាប់បានរៀនខ្មែរដែរទេ?

ខ៖ ខ្ញុំកាលពីមុនមកខ្ញុំរៀន តែឥឡូវនឹងខ្ញុំមើលអក្សរមិនឃើញទេនឹងហាស

ក៖ ចុះម៉ាក់យាយរៀនបានថ្នាក់ទីប៉ុន្មានដែរម៉ាក់យាយ?

ខ៖ ខ្ញុំរៀនបានថ្នាក់ទី4នឹង

ក៖ រៀនបានថ្នាក់ទី4ហោសម៉ាក់យាយ?

ខ៖ ចុះម៉ែឪក្រធ្វើស្រែនឹងហាស ធ្វើម៉េចបានរៀនច្រើនដូចគេដែរ ខ្ញុំនៅជួយរកម៉ែឪ

ក៖ ចុះកាលពីម៉ាក់យាយរៀននឹងតើម៉ាក់យាយរៀននៅណាដែរ?

ខ៖ ខ្ញុំរៀននៅកំពង់រ៉ូលនឹង

ក៖ អូ៎!បាទចុះឈ្មោះសាលាម៉ាក់យាយមានចងចាំទេ?

ខ៖ សាលាកំពង់រ៉ូលនឹង មិនដឹងថាសាលាអីគេទេនេះ វាយូរពេកហើយខ្ញុំវាលែងចាំហើយ ពីព្រោះវាចាស់ពេកហើយនឹងហាស

ក៖ អត់អីទេម៉ាក់យាយ ចុះម៉ាក់យាយធ្លាប់មានម្មិតភក្តិណាដែរធំធាត់មកជាមួយគ្នាដែរទេ?

ខ៖ អត់ទេ

ក៖ ចុះកាលពីមិត្តភក្តិនៅសាលាម៉ាក់យាយមានចងចាំឈ្មោះពួកគាត់ដែរទេ?

ខ៖ អត់ចាំគេទេ ពីព្រោះវាចេះតែបែកៗគ្នាចឹងទៅនរណាគេចាំបាន

ក៖ ចុះម៉ាក់យាយធ្លាប់មានអនុស្សាវរីយ៍អីជាមួយមិត្តភក្តិម៉ាក់យាយដែរទេម៉ាក់យាយ?

ខ៖ ចេះតែមានហើយតែឥឡូវនឹងគេស្លាប់បាត់ហើយនឹងហាស

ក៖ ប៉ុន្តែធ្លាប់ធ្វើអីគេខ្លះដែរម៉ាក់យាយ?

ខ៖ មានធ្វើអីគេទេ ទៅរៀនជាមួយគ្នាចឹងទៅ មានការជំនុំជាមួយគ្នាចឹងទៅណាស់

ក៖ លក្ខណះថានិយាយគ្នាលេងចឹងហោស?

ខ៖ នឹងហើយចឹង

ក៖ បាទម៉ាក់យាយ ចុះម៉ាក់យាយមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេម៉ាក់យាយ?

ខ៖  អត់ចេះទេ

ក៖  ចុះភាសាវៀតណាម ថៃអីចឹងហាស?

ខ៖  ទេមិនចេះទេ មិនដែរបានដើរទៅនាផងមានអីចេះទៅ

ក៖  បាទម៉ាក់យាយ
ចុះម៉ាក់យាយធ្លាប់ធ្វើការងារអីគេខ្លះដែរម៉ាក់យាយតាំងពីក្មេងរហូតមកដល់ពេលនេះហាស?

ខ៖  ខ្ញុំតាំងពីក្មេងមកនឹង?

ក៖  បាទម៉ាក់យាយធ្លាប់ធ្វើការងារអីគេខ្លះដែរម៉ាក់យាយ?

ខ៖  ពីក្មេងមកខ្ញុំគ្មានធ្វើអីទេ ខ្ញុំធ្វើតែស្រែនឹងដូចអ្វីដែរខ្ញុំជំរាប់ប្រាប់ចឹងហាស

ក៖  រហូតមកដល់ពេលដែរម៉ាក់យាយមានតា
ក៏ម៉ាក់យាយនៅតែធ្វើស្រែដែរហោសម៉ាក់យាយ?

ខ៖  នឹងហើយ មកដល់ពេលបច្ចុប្បន្ននឹងក៏ខ្ញុំគ្មានធ្វើអីគេដែរ

ក៖  បាទម៉ាក់យាយ ចុះម៉ាក់យាយមានធ្លាប់ទៅធ្វើស្រែចំការដែរទេម៉ាក់យាយ?

ខ៖  អត់មានទេ

ក៖  អត់ទេណាម៉ាក់យាយ ចុះម៉ាក់យាយមានធ្លាប់បើកអាជីវកម្មលក់ដូរអីគេទេ?

ខ៖  មិនដែរទេ ខ្ញុំមិនដែរបើកអាជីវកម្មអីទេនឹងហាស

ក៖  ប៉ុន្តែម៉ាក់យាយមានដែរចិញ្ចឹមមាន់ ចិញ្ចឹមទា គោ ក្របីអីទេ?

ខ៖  ទេរបស់ចឹងខ្ញុំមិនដែរចិញ្ចឹមអីទេ?

ក៖  អត់ទេហោសម៉ាក់យាយ?

ខ៖  ចាំ!នឹងហើយ

ក៖  ចុះម៉ាក់យាយគិតថា ជីវិតរបស់ម៉ាក់យាយមានការផ្លាស់ប្តូរអីគេខ្លះដែរម៉ាក់យាយ?

ខ៖  ផ្លាស់ប្តូរបានច្រើនណាស់កូនអើយ

ក៖  មានការផ្លាស់ប្តូរអីគេខ្លះដែរម៉ាក់យាយ?

ខ៖ ពីមុននឹងយើងកាចយោយៅហាស
ប៉ុន្តែដល់ពេលឥឡូវនឹងយើងទៅវត្តទៅវ៉ាអីចឹងហាស
ចឹងយើងចេះតែដកងាចិត្តកំហឹងយើងចោលខ្លះទៅ

ក៖ បាទត្រូវម៉ាក់យាយ?

ខ៖ អោយកូនៗនឹងវាបានរៀនតាមយើងចឹងហាស

ក៖ ត្រូវហើយម៉ាក់យាយ?

ខ៖ កុំអោយវាខឹងសំប៉ាអីចឹងហាស

ក៖ ចុះម្ហូបអីគេដែរម៉ាក់យាយគិតថា ម៉ាក់យាយចូលចិត្តពិសារជាងគេដែរម៉ាក់យាយ?

ខ៖ គ្មានម្ហូបអីទេ ខ្ញុំពិសារអីក៏បានដែរ

ក៖ ចុះម៉ាក់យាយគិតថាស្ងោរ ឆា ចៀន ម្ជូរ រឺក៏ម្ជូរយួន ការី
កកូរអីដែរម៉ាក់យាយគិតថាចូលចិត្តជាងគេចឹងហាស?

ខ៖ ខ្ញុំនិយាយរឿងជូខ្ញុំមិនសូវចេះហូបទេ ខ្ញុំចូលចិត្តតែក្រៀមៗទេនឹងហាស

ក៖ អូ៎!ក្រៀមៗណាម៉ាក់យាយ?

ខ៖ នឹងហើយក្រៀមៗនឹង

ក៖
ចុះកាលពីនៅក្មេងម៉ាក់យាយចូលចិត្តលេងល្បែងប្រជាប្រិយ៍អីគេដែរម៉ាក់យាយចូលចិត្ត
លេង ដូចជាបោះអង្គុញ ចោលឈូង លាក់កន្សែងមានចូលចិត្តលេងអីទេ?

ខ៖ ឪពុករបស់ខ្ញុំមិនអោយទៅលេងទេ

ក៖ ហេតុអីម៉ាក់យាយ?

ខ៖ ពីព្រោះតែល្បែងចូលឆ្នាំនឹងគ្មានទៅវត្តជាមួយគាត់នឹង
គាត់ថាមិនបាច់ទៅទេកូនខ្លួនយើងជាស្រីចឹងហាស

ក៖ អូ៎!ចឹងហោសម៉ាក់យាយ?

ខ៖ គេនិយាយដើមចឹង គេដើរមើលមកវាមិនសមរម្យចឹងហាស
ចឹងខ្ញុំធ្វើតាមពាក្យសម្ដីមួយនឹង ហើយយើងចេះតែសប្បាយដែរចឹងទៅ

ក៖ អូ៎!បាទម៉ាក់យាយចេះច្រៀងទេ?

ខ៖  អត់ខ្ញុំមិនចេះទេ

ក៖  ប៉ុន្តែម៉ាក់យាយចូលចិត្តស្តាប់បទចំរៀងទេ?

ខ៖  បើស្តាប់ចេះតែស្តាប់ចឹងទៅណាស់ តែបើអោយច្រៀងមិនចេះទេ

ក៖  ចុះម៉ាក់យាយគិតថា
មាននរណាគេនៅក្នុងក្រុមគ្រួសារចេះលេងឧបករណ៍ភ្លេងដែរទេម៉ាក់យាយ?

ខ៖  ខ្ញុំមិនសូវដឹងដែរនឹងកូនអើយ

ក៖  អតមានទេណម៉ាក់យាយ?

ខ៖  អត់មានទេ

ក៖
ចុះផ្ទះរបស់ម៉ាក់យាយមានលក្ខណះបែបណាដែរតាំងពីក្មេងរហូតមកដល់ពេលនេះហាស
ម៉ាក់យាយ?

ខ៖  ផ្ទះរបស់ខ្ញុំតាំងពីក្មេងមកនឹង

ក៖  បាទមានលក្ខណះបែបណាដែរម៉ាក់យាយ?

ខ៖  កូនៗវាពិបាក ហើយកូនៗវាក្រ រាល់ថ្ងៃនឹងទៅរើសអេតចាយ
រកមួយថ្ងៃបានតែមួយថ្ងៃទេ

ក៖  អូ៎!ចឹងហោសម៉ាក់យាយ?

ខ៖  ពេលដែរយើងទៅរកចឹងទៅបានថ្ងៃនឹងចឹងទៅណាស់
ពេលដែរស្អែកយើងទៅរកបានស្អែកទៅណាស់

ក៖  បាទត្រូវហើយម៉ាក់យាយ

ខ៖  ហើយណាលុយទឹក ប្រាប់ក្មួយត្រង់ទៅ
មិនទាន់មានលុយបង់ទឹកគេទេនេះយើងរកមិនបានទេ ប្រចាំថ្ងៃបានតែមួយថ្ងៃទេនឹងហាស

ក៖  បាទចឹងធ្វើម៉េចទៅ?

ខ៖  តែបើអោយបានលើសពីថ្ងៃនឹងយើងជំពាក់បំណុលគេ យើងត្រូវរកម្ហូបសិនណាស់

ក៖  ប៉ុន្តែផ្ទះនឹងជាផ្ទះរបស់ម៉ាក់យាយផ្ទាល់ហោសម៉ាក់យាយ?

ខ៖  ចា៎!ផ្ទះរបស់ខ្ញុំផ្ទាល់នឹងហាស

កៈ ប៉ុន្តែនរណាគេជាអ្នកសាងសងផ្ទះមួយនឹងដែរម៉ាក់យាយ?

ខៈ ខ្ញុំជាអ្នកសាងសងខ្លួនឯង តាំងពីខ្មោចតានៅមកហើយនឹងហាស

កៈ ប៉ុន្តែម៉ាក់យាយជួលគេធ្វើហើយអោយលុយគេទៅ?

ខៈ ចា៎!ជួលគេធ្វើនឹងហាស

កៈ ចុះគិតថាមានជំនាញអីដែរម៉ាក់យាយគិតថា
ម៉ាក់យាយចេះស្ទាត់ជំនាញដែរចឹងហាសម៉ាក់យាយ?

ខៈ ខ្ញុំមិនសូវចេះអីទេ កាលពីជំនាន់មុនមិនដូចជំនាន់ឥឡូវនឹងហាស

កៈ ដូចលក្ខណះវេញ វល្លិ៍ កូរស្ក ត្បាញក្រម៉ា ធ្វើជាកន្ទេល អញ្ចាត់កន្ទេល
រឺលក្ខណះថាជាធ្វើល្អីចឹងហាសម៉ាក់យាយ?

ខៈ អតចេះធ្វើសោះ

កៈ បាទម៉ាក់យាយ
ចុះឪពុកម្ដាយរបស់ម៉ាក់យាយធ្លាប់បង្រៀនពីជំនាន់អីទៅម៉ាក់យាយដែរទេម៉ាក់យាយ?

ខៈ ម៉ែរបស់ខ្ញុំនឹងគាត់បង្រៀនបានតែធ្វើស្រែនឹងហាស
និយាយអោយចប់ទៅគឺចេះធ្វើស្រែតែមួយមុខគត់នឹងហាស

កៈ អូ៎!ធ្វើស្រែហោសម៉ាក់ ចឹងម៉ាក់យាយជំនាញធ្វើស្រែនឹងហោសម៉ាក់យាយ?

ខៈ ធ្វើស្រែ នឹងហើយ

កៈ ចុះម៉ាក់យាយអាចប្រាប់បានទេ
ថាពេលណាដែរម៉ាក់គិតថាជាការលំបាកជាងគេនៅក្នុងជីវិតរបស់ម៉ាក់យាយដែរ?

ខៈ ថាដូចខ្ញុំប្រាប់មិញចឹង ដូចអ្វីដែរខ្ញុំប្រាប់លោកគ្រូឯងចឹង ថាខ្ញុំពិបាកណាស់
មួយទៀតនឹងហាស កាលពីយើងនៅជាមួយឪពុម្ដាយ យើងធ្វើស្រែរាំងស្ងួត

កៈ បាទម៉ាក់យាយ?

ខៈ ខ្ញុំរែកទឹកត្រីទូលយកទៅលក់

កៈ អូ៎!ចឹងហោសម៉ាក់យាយ?

ខៈ ខ្ញុំយកវៀតណាមមកលក់នឹង ហើយក៏រែកទឹកត្រីទូលចែកគ្នាលក់

កៈ ប្ដូរស្រូវ ចុះកាលពីជំនាន់ពលពតនឹងគេអោយម៉ាក់យាយធ្វើអីគេដែរម៉ាក់យាយ?

ខ៖ គេអោយខ្ញុំស្ទូង គេអោយខ្ញុំទៅដកនៅម៉ោង12គេអោយទៅ គេថាកង់មុខ កង់ក្រោយអីគេនោះ ខ្ញុំចេះតែទៅបើមិនទៅគេយកទៅវៃចោល បើចឹងយើងចេះតែទៅតាមគេទៅចឹងហាស

ក៖ បាទត្រូវម៉ាក់យាយ?

ខ៖ បើយើងមិនទៅមិនបានទេ កងទ័ពគេវៃយើងហើយនឹងហាស មុននឹងបែកវៀតណាមចូលមកប្រទេសកម្ពុជាយើងនឹង គេត្រាំអង្ករនុំបញ្ចុះនៅកន្លែងសហាករគេណាស់ ថាថ្ងៃនឹងគេត្រូវអេយហូបនុំបញ្ចុះហាសណាស់

ក៖ ចឹងហោសម៉ាក់យាយ?

ខ៖ គេហៅអោយហូបនុំបញ្ចុះទៅ ដល់ពេលម៉ោង8-9នឹងគេតគ្រាប់កាំភ្លើងក្តុងក្តាំងៗៗ ទៅក៏ខ្ញុំនាំកូនរៀបចំឥវ៉ាន់ដើរចេញមកនឹងហាស

ក៖ បាទម៉ាក់យាយ?

ខ៖ ខ្ញុំថាកូនអើយកុំនៅ នៅមិនបានទេយើងមកភ្នំពេញទៅបើថាស្លាប់ក៏ស្លាប់នៅភ្នំពេញទៅកូន

ក៖ អូ្ន!ចឹងហោសម៉ាក់យាយ ចុះពេលណុងគេអោយម៉ាក់យាយជំលាសទៅណាដែរម៉ាក់យាយ?

ខ៖ ខ្ញុំគេអោយជំលាសទៅភ្នំស្រង់ ប៉ុន្តែខ្ញុំអត់ទៅទេណាស់

ក៖ ភ្នំស្រង់នៅណាវិញម៉ាក់យាយ?

ខ៖ ភ្នំស្រង់នៅខេត្តកំពង់ស្ពឺហោស

ក៖ អូ្ន!នៅខេត្តកំពង់ស្ពឺហោស?

ខ៖ ប៉ុន្តែខ្ញុំអត់ទៅទេនឹងហាស ខ្ញុំជំលាសខ្លួនមកភ្នំពេញទៅ បើស្លាប់ក៏ស្លាប់ទៅណាស់នាំកូនរែកសង្រែកមកភ្នំពេញទៅណាស់

ក៖ អូ្ន!ចឹងហោសម៉ាក់យាយ?

ខ៖ បើស្លាប់ក៏មិនដឹងថាធ្វើម៉េចទេណាស់

ក៖ ចុះម៉ាក់យាយគិតថាឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរម៉ាក់យាយ?

ខ៖ ឆ្លងកាត់ការលំបាកនឹងដោយធ្ងន់ធ្ងរណាស់លោកកូន

ក៖ ដូចថាម៉ាក់យាយឆ្លងកាត់ឧបសគ្គមួយនឹងហាស?

ខ៖ ធ្ងន់ធ្ងរណាស់ ដេកតាមភ្លឺស្រែ ដេកតាមព្រៃឈើ ទៅកំបង់ទឹកហូប
នឹងទៅយកការមួយមកដួសទឹកអោយកូនហូប ខ្ញុំធ្ងន់តែមែនទែនទៅណាស់

ក៖ អូ៎!នេះជាការឆ្លងកាត់ឧបសគ្គរបស់ម៉ាក់យាយណាម៉ាក់យាយ?

ខ៖ នឹងហើយ

ក៖
ចុះពេលដែរម៉ាក់យាយមានគ្រួសារម៉ាក់យាយគិតថាម៉ាក់យាយមានការលំបាកអីគេខ្លះដែរម៉ាក់យាយ?

ខ៖ ខ្ញុំប្រាប់ដែរតើថា ខ្ញុំនៅក្មេងខ្ញុំមានទុកលំបាកវេទនា
តែដល់ពេលយើងមានគ្រួសារមកទើបយើងធូរ ពេលយើងមានប្ដីយើងបានធូរបន្តិចហាស

ក៖ បាទចឹងហោសម៉ាក់យាយ?

ខ៖ កាលពីមុនមកវាពិបាកវេទនា ពិបាកពីរឿងអាពត ពីរនាក់ប្ដីប្រពន្ធហាស
គាត់ថាអោយច្រើនហាស គាត់ថាយាយអើយ យាយឯងខំប្រឹងមើលកូនចៅ
ហើយខ្ញុំក៏មិនហ៊ានអោយកូនចៅដើរទៅណាផ្ដេសផ្ដាស់ដែរនឹងហាស
នៅតែក្នុងផ្ទះទៅកូនអោយកុំអោយ
ថាយើងក្របបរមួយចានក៏នៅក្នុងផ្ទះយើងដែរនឹងហាស
គ្មានអ្នកក្រៅណាគេអោយយើងទេ

ក៖ ចុះម៉ាក់យាយមានក្ដីស្រម៉ៃណាបីក្មេងទេ?

ខ៖ អត់មានទេ

ក៖ ចុះបើចង់អោយម៉ាក់យាយផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗ
តើម៉ាក់យាយចង់ផ្ដែផ្ដាំអីទៅពួកគាត់ដែរម៉ាក់យាយ?

ខ៖ ខ្ញុំផ្ដាំចឹង ខ្ញុំផ្ដាំថាម៉ែអើយពិបាកណាស់កូន កូនឯងនៅតាមក្រោយ
កុំអោយពិបាកដូចម៉ែទៀតខំរកទៅបានប៉ុណ្ណាហូបប៉ុណ្ណឹងទៅណាស់ ថាកុំអោយដើរលួចដើធក់របស់គេ ខ្ញុំបានផ្ដែផ្ដាំកូនរបស់ខ្ញុំតែប៉ុណ្ណឹងឯង

ក៖ ចុះមានអីចង់ផ្ដែផ្ដាំទៀតទេ?

ខ៖  គ្មានទេ

ក៖
ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនម៉ាក់យាយដែរបានអោយខ្ញុំបានសំភាសន៍ជាមួយម៉ាក់យាយចឹងហាស បាទអរគុណច្រើនម៉ាក់យាយ៕៕៕